ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
នីតិវិធី ការបង្កើត ការចាត់ថ្នាក់ និង ការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

៙ ✻ ៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋាន រុក្ខា-ប្រមាញ់ ទៅជា រដ្ឋបាលព្រៃឈើ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៥

www.pheakdeylaw.com

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់នូវ នីតិវិធី ការបង្កើត ការចាត់ថ្នាក់ និង ការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍ សំដៅរៀបចំ និង គ្រប់គ្រងផ្ទៃដីព្រៃឈើ និង ធនធានព្រៃឈើប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយ និង ផែនការគ្រប់គ្រងវិស័យព្រៃឈើជាតិ ។

មាត្រា ២.-

សម្បត្តិព្រៃឈើអចិន្ត្រៃយ៍រួមមាន :

១- ព្រៃបម្រុងទុកអចិន្ត្រៃយ៍ គឺជាព្រៃឈើរដ្ឋដែលគ្របដណ្តប់លើដី ដែលមិនមែនជាកម្មសិទ្ធិឯកជននិង ដែលត្រូវចាត់ថ្នាក់ជាបី (៣) ប្រភេទ គឺ÷

ក- ព្រៃផ្តល់ផល

ខ- ព្រៃការពារ

គ- ផ្ទៃដីព្រៃសម្រាប់ផ្ទេរដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត ។

២- ព្រៃឯកជន គឺជាចំការឈើដែលបានដាំ ឬ ដើមឈើដែលដុះដោយធម្មជាតិលើដីដែលបានចុះបញ្ជីកា និង ផ្តល់ ជាកម្មសិទ្ធិឯកជនក្រោមនីតិវិធី និង ច្បាប់រដ្ឋ ។

ជំពូកទី ២

ការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍

មាត្រា ៣.-

ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានភារកិច្ចសិក្សា កំណត់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍នៅទូទាំងប្រទេស ដោយផ្អែកតាមផែនទីគម្របព្រៃឈើ ទិន្នន័យផ្ទៃដីព្រៃឈើ និង ផ្ទៃដីមិនមែនព្រៃឈើ និយាមកាច្បាស់លាស់ ដោយត្រូវកសាងជាផែនទីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ថ្នាក់ជាតិ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវចេញសេចក្តីប្រកាសជូនដំណឹងជាផ្លូវការ តាមរយៈប្រព័ន្ធ ផ្សព្វផ្សាយ និង បិទផ្សាយនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋបាលព្រៃឈើ នៅតាមសាលាខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ព្រមទាំងខណ្ឌរដ្ឋបាលព្រៃឈើសាមី ដោយបញ្ជាក់នូវព័ត៌មានជាអាទិ៍ : ផែនទីដែល បង្ហាញទីតាំង ទំហំ ព្រំប្រទល់ និយាមកា ផ្ទៃដីព្រៃឈើ ផ្ទៃដីមិនមែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ផ្ទៃដីព្រៃបម្រុងទុក អចិន្ត្រៃយ៍ ក្នុងខេត្ត ក្រុងនីមួយៗ ។

www.pheakdeylaw.com

មាត្រា ៤ .-

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តាមរយៈខណ្ឌរដ្ឋបាលព្រៃឈើ ត្រូវទទួលពាក្យតវ៉ាជាលាយលក្ខណ៍អក្សរក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្ដីប្រកាសជូនដំណឹង ។

ក្នុងករណីគ្មានពាក្យតវ៉ា ផ្ទៃដីព្រៃឈើខាងលើ ត្រូវក្លាយជាដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍តាមនីតិវិធី ។

មាត្រា ៥ .-

ត្រូវបង្កើតគណៈកម្មាធិការថ្នាក់ជាតិមួយ ដើម្បីដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។ គណៈកម្មាធិការថ្នាក់ជាតិ មានសមាសភាព ដូចខាងក្រោម ÷

១- រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	ជាប្រធាន
២- រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ	ជាអនុប្រធាន
៣- រដ្ឋលេខាធិការ ក្រសួងការពារជាតិ	ជាអនុប្រធាន
៤- អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៥- អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៦- អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧- អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន	សមាជិក
៨- អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌	សមាជិក
៩- អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
១០- អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ	សមាជិក
១១- អគ្គស្នងការនគរបាលជាតិ	សមាជិក
១២- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
១៣- ប្រធានរដ្ឋបាលព្រៃឈើ	លេខាធិការ

ប្រធានគណៈកម្មាធិការថ្នាក់ជាតិដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ អាចអញ្ជើញតំណាងក្រសួង ស្ថាប័នផ្សេងទៀតចូលរួមប្រជុំតាមការចាំបាច់ ។

គណៈកម្មាធិការថ្នាក់ជាតិនេះ មានលេខាធិការដ្ឋានប្រតិបត្តិនៅរដ្ឋបាលព្រៃឈើ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

មាត្រា ៦ .-

គណៈកម្មាធិការថ្នាក់ជាតិដោះស្រាយបាតុភាព ក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ មានតួនាទី និងភារកិច្ច ដូចតទៅ ÷

១- ពិនិត្យពាក្យតវ៉ាក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍តាមខេត្ត ក្រុងនីមួយៗ ។

www.pheakdeylaw.com

២- ដោះស្រាយបាតុភាពតវ៉ា ដោយផ្អែកតាមការវាយតម្លៃរួមជាក់ស្តែងដល់មូលដ្ឋាន និង អនុលោមតាមមូលដ្ឋានច្បាប់ស្តីពីព្រៃឈើ និង ច្បាប់ពាក់ព័ន្ធ ។

៣- ពិនិត្យ កែតម្រូវ ឬ រំសាយចោលនូវការប្រើប្រាស់ដីព្រៃឈើណា ដែលរំលោភបំពាន ឬ កាន់កាប់ដីព្រៃឈើរបស់រដ្ឋ ផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ ។

៤- ធ្វើកិច្ចសហប្រតិបត្តិការ និង សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ ឬ យន្តការពាក់ព័ន្ធផ្សេងទៀត ដើម្បីដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ឱ្យមានប្រសិទ្ធភាព ។

៥- បង្កើតអនុគណៈកម្មាធិការថ្នាក់ខេត្ត ក្រុង ដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបំរុងទុកអចិន្ត្រៃយ៍តាមការចាំបាច់ ដែលមានឯកឧត្តមអភិបាលខេត្ត ក្រុងសាមី ជាប្រធាន ដើម្បីបំពេញភារកិច្ចជាយន្តការចុះពិនិត្យ ស្រាវជ្រាវ និង វាយតម្លៃផ្ទាល់ដល់មូលដ្ឋាន ។

៦- ធ្វើរបាយការណ៍ និង លើកអនុសាសន៍ជូនរាជរដ្ឋាភិបាលលើដំណើរការដោះស្រាយបាតុភាព ក្នុងការបង្កើតដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ។

មាត្រា ៧ .-

ក្នុងករណីមានបាតុភាព ឬ មានពាក្យតវ៉ាដែលមិនអាចដោះស្រាយបាន គណៈកម្មាធិការថ្នាក់ជាតិដោះស្រាយបាតុភាពក្នុងការបង្កើតដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ ត្រូវស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល ។

ផ្នែកណាមួយនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍តាមខេត្ត ក្រុងនីមួយៗ ដែលស្ថិតក្រោមបាតុភាពតវ៉ា ត្រូវរក្សាទុករង់ចាំការដោះស្រាយ និង សម្រេចពីរាជរដ្ឋាភិបាល ។ ក្នុងរយៈពេលរង់ចាំការដោះស្រាយ គ្មានស្ថាប័ន ឬ អាជ្ញាធរណាមួយ មានសិទ្ធិចេញលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ ប័ណ្ណសម្គាល់កម្មសិទ្ធិ នៅលើដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ដែលមានបាតុភាពនោះឡើយ ។

រាល់ដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដែលពុំមានបាតុភាពតវ៉ា ឬ បានដោះស្រាយបាតុភាពរួច ត្រូវប្រកាសជាផ្លូវការតាម រយៈអនុក្រឹត្យស្តីពីការបង្កើតដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

មាត្រា ៨ .-

រាល់ផ្ទៃដីព្រៃឈើរបស់រដ្ឋទាំងឡាយ ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ដែលបានបង្កើតឡើងតាមរយៈអនុក្រឹត្យ ឬ លិខិតបទដ្ឋាននានារបស់រាជរដ្ឋាភិបាល ឬ តាមរយៈប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅមុនពេលអនុក្រឹត្យនេះចូលជាធរមាន ត្រូវបញ្ចូលដោយស្វ័យប្រវត្តិទៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ តាមនីតិវិធីដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

www.pheakdeylaw.com

ជំពូកទី ៣
ការចាត់ថ្នាក់ ចុះបញ្ជិកាព្រៃបម្រុងទុកអចិន្ត្រៃយ៍

មាត្រា ៩ .-

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មានសិទ្ធិចេញប្រកាសចាត់ថ្នាក់ ចុះបញ្ជិកាព្រៃបម្រុងទុកអចិន្ត្រៃយ៍ ក្រោមចំណាត់ថ្នាក់ណាមួយក្នុងចំណោមចំណាត់ថ្នាក់ ដូចមានចែងក្នុង មាត្រា ១០ កថាខណ្ឌទី ២ ចំណុចទី ១ ចំណុចទី ២ និង ចំណុចទី ៣ នៃច្បាប់ស្តីពីព្រៃឈើ ស្របតាមមុខងារនៃប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ និង សារៈសំខាន់របស់ព្រៃឈើសម្រាប់តម្រូវការ សេដ្ឋកិច្ច សង្គម និង វប្បធម៌ ។

មាត្រា ១០ .-

រដ្ឋបាលព្រៃឈើមានភារកិច្ច ក្នុងដំណើរការចាត់ថ្នាក់ និង ចុះបញ្ជិកាព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម ÷

១- ចុះអង្កេត វាស់វែងចំណុចនិយាមកា និង សិក្សាស្ថានភាពព្រៃឈើជាក់ស្តែងដែលនឹងត្រូវចាត់ថ្នាក់ផ្អែកតាមផែនទីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដោយប្រមូលទិន្នន័យអំពីប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ធនធានព្រៃឈើ និង ព័ត៌មានអំពីតម្រូវការ សង្គម-សេដ្ឋកិច្ច និង សក្តានុពលផ្សេងទៀត របស់ព្រៃបម្រុងទុកអចិន្ត្រៃយ៍តាមតំបន់ ឬ ភូមិសាស្ត្រព្រៃឈើ នីមួយៗ ។

២- ធ្វើការវិភាគលើទិន្នន័យ និង ព័ត៌មាន ដែលប្រមូលបានក្នុងតំបន់ ឬ ភូមិសាស្ត្រព្រៃឈើនីមួយៗ ដើម្បីធ្វើ អត្តសញ្ញាណព្រៃបម្រុងទុកអចិន្ត្រៃយ៍ទៅតាមចំណាត់ថ្នាក់នីមួយៗ ។

៣- ដៅចំណុចនិយាមកាសម្គាល់ព្រំសីមាគោល របស់ចំណាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ នៅលើផែនទីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងនៅលើទីកន្លែងជាក់ស្តែង ដោយកំណត់យកព្រំធម្មជាតិជាអាទិភាពដូចជា ផ្លូវ អូរ ស្ទឹង ព្រែក ជួរខ្នងភ្នំ

៤- ធ្វើការសម្របសម្រួល និង ពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន ឬ សមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសម្រួលដល់ដំណើរការចាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នៅតាមខេត្ត ក្រុង នីមួយៗ ។

៥- រៀបចំឯកសារសម្រាប់គម្រោងចំណាត់ថ្នាក់ ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ ដោយកំណត់នូវទីតាំងភូមិសាស្ត្រ ទីតាំងរដ្ឋបាល ព្រំប្រទល់ និង និយាមកាច្បាស់លាស់ ព្រមទាំងបង្ហាញពីសារៈសំខាន់ និង គោលបំណងសំខាន់ក្នុងការចាត់ថ្នាក់ ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ និង ទិសដៅអនាគតក្នុងការប្រើប្រាស់ និង ការគ្រប់គ្រងចំណាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ ។

មាត្រា ១១ .-

រដ្ឋបាលព្រៃឈើ ត្រូវបញ្ជូនគម្រោងសំណើចាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដោយភ្ជាប់នូវសំណុំឯកសារ ផែនទី និង របាយការណ៍ស្តីពីដំណើរការរៀបចំចាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នោះតាមនីតិវិធី ដើម្បីស្នើសុំប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

www.pheakdeylaw.com

ប្រភេទចំណាត់ថ្នាក់ព្រៃបម្រុងទុកអចិន្ត្រៃយ៍នីមួយៗ ត្រូវមានអត្តលេខចុះបញ្ជិកាដែលផ្តល់ និង តម្កល់ទុកនៅរដ្ឋបាលព្រៃឈើ សម្រាប់សម្គាល់ជាអត្តសញ្ញាណនៃព្រៃបម្រុងទុកអចិន្ត្រៃយ៍នោះ ។

ជំពូកទី ៤
ការបង្កើត ការចាត់ថ្នាក់ ចុះបញ្ជិកាព្រៃឯកជន

មាត្រា ១២ .-

នីតិវិធី ការបង្កើត ការចាត់ថ្នាក់ ចុះបញ្ជិកាព្រៃឯកជន ត្រូវកំណត់ដោយប្រកាសស្តីពីវិធានព្រៃឯកជន របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ជំពូកទី ៥
អវសានប្បញ្ញត្តិ

មាត្រា ១៣ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៤ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ១៤
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com